# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងអាណត្តិទី២ :

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | ឯកឧត្តម **ម៉ប់ សារិន** | ១០-០២-១៩៥២ | ជាប្រធានក្រុមប្រឹក្សារាជធានី |
| ២- | ឯកឧត្តម **សួន រិនឌី** | ០១-០៨-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សារាជធានី |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តម **ជួប ខុន** | ០៣-១០-១៩៥៨ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៤- | លោកជំទាវ **មុំ សណ្ដាប់** | ២៩-១១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៥- | ឯកឧត្តម **ឡូ យុយ** | ១០-១០-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៦- | លោកជំទាវ **មុំ គ្រសាល** | ០១-០៦-១៩៥២ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៧- | ឯកឧត្តម **ល័ស រី** | ០១-០១-១៩៤០ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៨- | លោកជំទាវ **ឃួន គីមនី** | ១៤-០៥-១៩៥៩ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៩- | ឯកឧត្តម **នុត ជា** | ២៧-០៧-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១០- | ឯកឧត្តម **ម៉ម យុធ** | ០៧-១២-១៩៥០ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១១- | ឯកឧត្តម **ព្រហ្ម គន្ធ** | ១៨-០៩-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១២- | ឯកឧត្តម **វ៉េង ថៃ** | ០៥-០៣-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៣- | ឯកឧត្តម **ហែម ឡុងសុភ័ក្ត្រ** | ១៦-១០-១៩៧៩ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៤- | ឯកឧត្តម **ខៃត ចន្ថាវី** | ០១-០៨-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៥- | ឯកឧត្តម **ផន សុគីម** | ០១-០៣-១៩៥១ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៦- | ឯកឧត្តម **ម៉ន ផល្លា** | ២០-០៥-១៩៧៥ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៧- | ឯកឧត្តម **សុក សេក** | ០១-០១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៨- | ឯកឧត្តម **ភាក់ កុម្ភារ** | ១៧-០២-១៩៦៦ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៩- | លោកជំទាវ **យក់ នាង** | ១០-០៨-១៩៥៩ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ២០- | ឯកឧត្តម **គីម សុតា** | ១០-១១-១៩៨០ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ២១- | ឯកឧត្តម **ផាត់ ផល្លា** | ០៣-០៩-១៩៧៣ | ជាសមាជិកក្រុមប្រឹក្សារាជធានី។ |

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៤០៥.៦៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤

លេខ: ៦៥៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**